ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៣៤០ សង៣

ថ្ងៃសុក្រ ៣ កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៥

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ៖** ស្ដីពីការពង្រឹងលើការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌ សម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលនៅរដ្ឋបាលរាជធានី ខេត្ត។

**យោង** ៖ - អនុក្រឹត្យលេខ១៩៣ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការប្រគល់មុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

- ប្រកាសអន្តរក្រសួងលេខ១៨២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ស្ដីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្ត សម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាល
- ប្រកាសលេខ២៤៩ សហវ.ប្រក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា។

សេចក្ដីមានដូចចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត** ជ្រាបថា កន្លងមក រាជរដ្ឋាភិបាលបានសម្រេចប្រគល់មុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត តាមរយៈអនុក្រឹត្យលេខ១៩៣ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការប្រគល់មុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។ ទន្ទឹមនេះ មន្ទីរសុខាភិបាល និងបុគ្គលិកសុខាភិបាលដែលស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរសុខាភិបាលក៏ត្រូវបានផ្ទេរ និងធ្វើសមាហរណកម្មបញ្ចូលទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត ចាប់តាំងពីឆ្នាំ២០២០ ហើយក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាលបានដាក់ឱ្យអនុវត្តប្រកាសអន្តរក្រសួងស្ដីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្ត សម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាល ចាប់ពីឆ្នាំ២០២១រហូតដល់បច្ចុប្បន្ន តាមបែបផែននៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារនេះផងដែរ។



ទីស្ដីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh

ផ្អែកតាមមូលដ្ឋានដូចបានបញ្ជាក់ខាងលើ ក្រសួងមហាផ្ទៃសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងយកចិត្តទុកដាក់របស់រដ្ឋបាលរាជធានី ខេត្ត ក្នុងការអនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលនៅរដ្ឋបាលរាជធានី ខេត្ត តាមរយៈការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារនេះ មានភាពល្អប្រសើរ ប្រកបដោយគុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពស្របតាមគោលការណ៍ លក្ខខណ្ឌ និងនីតិវិធីនានាដែលបានកំណត់។ ទន្ទឹមនឹងភាពវិជ្ជមានខាងលើ ក្រសួងមហាផ្ទៃក៏បានកត់សម្គាល់ឃើញមានចំណុចខ្វះខាតមួយចំនួន ពាក់ព័ន្ធនឹងភារកិច្ចទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្តក្នុងការតាមដាន ត្រួតពិនិត្យ និងគាំទ្រកិច្ចលទ្ធកម្មដែលអនុវត្តដោយមន្ទីរសុខាភិបាល និងការតាមដាន និងត្រួតពិនិត្យលើការបំពេញការងាររបស់ប្រធានមន្ទីរសុខាភិបាលលើការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិការបស់មន្ទីរសុខាភិបាលផងដែរ។

ពាក់ព័ន្ធនឹងករណីនេះ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំដល់ ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបន្តយកចិត្តទុកដាក់ អនុវត្តនូវកិច្ចការសំខាន់ៗឱ្យបានខ្ជាប់ខ្ជួនស្របតាមគោលការណ៍ លក្ខខណ្ឌ និងនីតិវិធីពាក់ព័ន្ធនានាដូចខាងក្រោម៖

### ១. អំពីកិច្ចលទ្ធកម្មសាធារណៈរបស់មន្ទីរសុខាភិបាល

ផ្អែកតាមប្រកាសលេខ២៤៩ សហវ.ប្រក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ដូចមានយោងខាងលើ មន្ទីរសុខាភិបាលដែលជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិទទួលបានប្រតិភូកម្មពីអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបង្កើតឱ្យមានក្រុមលទ្ធកម្មផ្ទាល់របស់ខ្លួនសម្រាប់ដឹកនាំ និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់មន្ទីរសុខាភិបាល។ ក្រុមលទ្ធកម្មនេះត្រូវបង្កើតឡើង ដោយសេចក្តីសម្រេចរបស់អភិបាលរាជធានី ខេត្តដែលមានប្រធានមន្ទីរសុខាភិបាលជាប្រធាន និងមានសមាសភាព ដូចមានកំណត់ក្នុងប្រការ៦នៃប្រកាសខាងលើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទន្ទឹមនេះ មន្ទីរសុខាភិបាលត្រូវពង្រឹងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់ខ្លួនឱ្យបានត្រឹមត្រូវស្របតាមគោលការណ៍ និងនីតិវិធីលទ្ធកម្មសាធារណៈដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ប្រធានមន្ទីរសុខាភិបាលដែលជាប្រធានក្រុមលទ្ធកម្ម ត្រូវរៀបចំរបាយការណ៍តាមការកំណត់ និងដាក់ជូនអភិបាលរាជធានី ខេត្ត ដើម្បីជ្រាប និងតាមដាន ត្រួតពិនិត្យ និងផ្តល់ការគាំទ្រ។

### ២. ការទូទាត់ ឬបើកប្រាក់របស់មន្ទីរសុខាភិបាល

ផ្អែកតាមប្រកាសអន្តរក្រសួងលេខ១៨២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ដូចមានយោងខាងលើ ប្រធានមន្ទីរសុខាភិបាលដែលជាអាណាប័កផ្ទេរសិទ្ធិត្រូវបោះផ្សាយអាណត្តិបើកប្រាក់

ឈ

ដោយផ្ទាល់ និងបញ្ជូនទៅប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជាអភិបាលហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងផ្ដល់ទិដ្ឋាការ ហើយបញ្ជូនទៅរតនាគាររាជធានី ខេត្ត ដើម្បីធ្វើការទូទាត់ ដោយពុំតម្រូវឱ្យមានការសុំយោបល់ឯកភាពជាមុនពីអភិបាលរាជធានី ខេត្តឡើយ។ ពាក់ព័ន្ធនឹងបញ្ហានេះ អភិបាល នៃគណៈអភិបាលរាជធានី ខេត្តដែលជាអាណាប័កដើមខ្សែនៃថវិកា ត្រូវតាមដាន និងត្រួតពិនិត្យលើការបំពេញការងាររបស់ប្រធានមន្ទីរសុខាភិបាលពាក់ព័ន្ធនឹងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិការបស់មន្ទីរសុខាភិបាល ដើម្បីធានាឱ្យថវិកាទាំងនោះត្រូវបានគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បានត្រឹមត្រូវ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងឆ្លើយតបទៅនឹងគោលនយោបាយជាតិនៃវិស័យសុខាភិបាល។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត** ជ្រាប និងបន្តចាត់ចែងដូចខ្លឹមសារខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការរាប់អានពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**ចម្លងជូន ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសុខាភិបាល
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
- អគ្គាធិការដ្ឋាន ក្រសួងមហាផ្ទៃ
- ឯកសារ-កាលប្បវត្តិ